# សុន្ទរកថា
## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
## ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
## ថ្លែងក្នុងឱកាសអបអរសាទរ ទិវាជាតិអាហារូបត្ថម្ភ លើកទី៥
## (៦ វិច្ឆិកា ២០១៤ - ៦ វិច្ឆិកា ២០១៨)
## ក្រោមប្រធានបទ
## "ផ្តល់អាហារូបត្ថម្ភល្អដល់កូនអ្នក គឺជាការវិនិយោគដ៏ប្រសើរបំផុត"
## ទីស្តីការគណៈរដ្ឋមន្ត្រី, ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ២០១៨

- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំអង្គការដៃគូអភិវឌ្ឍន៍
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្មួយៗនិស្សិត និងសមាជិកសមាជិកា នៃអង្គពិធីទាំងមូលជាទីមេត្រី !

១. ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានមកចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងក្មួយៗ និស្សិតទាំងអស់ ក្នុងពិធីប្រារព្ធខួប **ទិវាជាតិអាហារូបត្ថម្ភលើកទី ៥ (៦ វិច្ឆិកា ២០១៤ - ៦ វិច្ឆិកា ២០១៨)** ក្រោមប្រធានបទ "**ផ្តល់អាហារូបត្ថម្ភល្អដល់កូនអ្នក គឺជាការវិនិយោគដ៏ប្រសើរបំផុត**"។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ សមាជិក សមាជិកា នៃអង្គពិធីទាំងមូល ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីដ៏មានអត្ថន័យនេះ ក្នុងគោលបំណងអប់រំ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈឲ្យបានទូលំទូលាយ អំពីសារៈសំខាន់របស់អាហារូបត្ថម្ភ និងការផ្តល់អាហារូបត្ថម្ភល្អដល់កុមារ គឺជាការវិនិយោគសម្រាប់ការអភិវឌ្ឍសង្គម មូលធនមនុស្ស សេដ្ឋកិច្ចជាតិ និងលើកទឹកចិត្តឲ្យយើងទាំងអស់គ្នា បង្កើនការវិនិយោគទៅលើអាហារូបត្ថម្ភ ក្នុងគោលដៅដើម្បីឲ្យកុមារ និងស្ត្រីមានសុខភាពល្អ ប្រសិទ្ធភាពការងារខ្ពស់ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិយើង។

២. ការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភសម្រាប់ជនគ្រប់រូប ពិសេសស្ត្រី និងកុមារ គឺជាកត្តាមិនអាចខ្វះបានសម្រាប់ធនធានមនុស្សជំនាន់ក្រោយ ពីព្រោះកុមារ គឺជាទំពាំងស្នងឫស្សីនៃប្រទេសជាតិ

នីមួយៗ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ដល់ការថែទាំសុខភាព និងការរៀនសូត្ររបស់ពួកគេ។ ឈរលើស្មារតីនេះហើយ ដែលការបង្កើនការវិនិយោគលើអាហារូបត្ថម្ភ និងការអន្តរាគមន៍ពហុវិស័យដើម្បីដោះស្រាយបញ្ហាអាហារូបត្ថម្ភ គឺមានសារៈសំខាន់ និងសារៈប្រយោជន៍ជាទីបំផុត ដើម្បីឱ្យកម្ពុជាយើងអាចសម្រេចគោលដៅអភិវឌ្ឍដោយចីរភាពឆ្នាំ ២០៣០ គឺ "**មិនទុកឲ្យនរណាម្នាក់មានបញ្ហាកង្វះស្បៀង និងរងគ្រោះពីបញ្ហាអាហារូបត្ថម្ភ**" ពិសេសគោលដៅទី២ នៃគោលដៅអភិវឌ្ឍន៍ដោយចីរភាពគឺ "**បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបាននូវសន្តិសុខស្បៀង លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងកសិកម្មប្រកបដោយចីរភាព**"។

៣. យោងតាមលទ្ធផលសិក្សាបែបវិទ្យាសាស្ត្រ លើបញ្ហាអាហារូបត្ថម្ភបានបង្ហាញថារាល់ការវិនិយោគចំនួន ០១ដុល្លារ លើអាហារូបត្ថម្ភ យើងនឹងបានទទួលផលដោយប្រយោលមកវិញចំនួន ១៦ដុល្លារ តាមរយៈការបង្កើនមូលធនមនុស្ស ប្រសិទ្ធភាពការងារ និងកំណើនសេដ្ឋកិច្ចជាតិ។ ដោយឡែក ការសិក្សារបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជាមួយនឹងដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៣ បានបង្ហាញថា បញ្ហាកុមារកង្វះអាហារូបត្ថម្ភ កុមារក្រិសក្រិន និងស្គមស្គាំង ឬ មានជំងឺផ្សេងៗ នឹងធ្វើឲ្យមានការប៉ះពាល់សេដ្ឋកិច្ចមានទំហំប្រមាណ ១.៧% នៃផលិតផលសរុបក្នុងស្រុក ក្នុងនោះយើងក៏ត្រូវមានការប្រុងប្រយ័ត្នផងដែរលើបញ្ហាជំងឺធាត់លើសទំងន់ និងជំងឺមិនឆ្លងនានា ក៏ជាបញ្ហាសង្គមដែលស្ថាប័នមានសមត្ថកិច្ចត្រូវគិតគូរ និងសហការគ្នាដើម្បីការពារទប់ស្កាត់ ជាពិសេសការប្រយុទ្ធនឹងបញ្ហាកង្វះអាហារូបត្ថម្ភគ្រប់ទម្រង់ តាមរយៈការផ្តល់របបអាហារដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ និងចម្រុះមុខ ដូចជាបន្លែ ផ្លែឈើស្រស់ ត្រី សាច់ និងស៊ុត ឲ្យបានច្រើនគ្រប់មុខ និងទៀងទាត់ ដើម្បីធ្វើឲ្យរាងកាយលូតលាស់បានល្អ។

៤. ក្នុងនាមសម្តេចតេជោនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមលើកទឹកចិត្តដល់មាតា-បិតា អាណាព្យាបាលកុមារ និងស្ត្រីជាម្តាយ សូមអនុវត្តទម្លាប់ដ៏វិជ្ជមានក្នុងការចិញ្ចឹមបីបាច់កូនៗរបស់ខ្លួន ដោយបំបៅកូនដោយទឹកដោះម្តាយសុទ្ធ រយៈពេលយ៉ាងតិចបំផុត ៦ ខែ និងផ្តល់ឱកាសកុមារចាប់ពីអាយុ ៦ ខែ ឡើងទៅបានទទួលទានបន្លែ ផ្លែឈើ ត្រី សាច់ និងស៊ុត ដើម្បីឲ្យពួកគេមានការលូតលាស់ល្អ ទាំងរាងកាយ និងបញ្ញាស្មារតីក្នុងការរៀនសូត្រ។ ការផ្តល់អាហារដែលសំបូរសារធាតុចិញ្ចឹមគ្រប់គ្រាន់ គឺវាមានភាពចាំបាច់ខ្លាំងណាស់សម្រាប់ការលូតលាស់ដែលជួយពួកគេឲ្យមានការអភិវឌ្ឍទាំងរូបរាងកាយ បញ្ញាស្មារតី និងប្រព័ន្ធបន្តពូជ។ ក្នុងន័យនេះ **ការវិនិយោគលើការផ្តល់អាហារូបត្ថម្ភល្អ** សម្រាប់កុមារក្នុងវ័យសិក្សា វាមិនត្រឹមតែគាំទ្រដល់សុខុមាលភាពកុមារប៉ុណ្ណោះទេ ប៉ុន្តែបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតមូលធនមនុស្ស បង្កើនផលិតភាពការងារ និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសជាតិយើងផងដែរ។

**អង្គពិធីនាំងមូលជាទីមេត្រី** !

៥.	គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងអាណត្តិទី៦ នេះ ក៏ដូចជាអាណត្តិមុនៗ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី គឺពង្រឹងតួនាទីវិស័យកសិកម្មក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង លើកកម្ពស់អាហារូបត្ថម្ភ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ។ ជាក់ស្តែង វិស័យកសិកម្មបានផ្តល់ការងាររហូតដល់ ៤១,៥% នៅតាមជនបទ ហើយកម្ពុជាបានផលិតស្បៀងលើសពីតម្រូវការក្នុងស្រុក ព្រមទាំងបានផលិត និងនាំចេញកសិផលជាច្រើនមុខ ជាពិសេសបាននាំចេញអង្ករជាង ៦០ ម៉ឺនតោន ក្នុងឆ្នាំ២០១៧ ហើយអង្ករកម្ពុជាក៏ទទួលបាននូវការលើកតម្កើងកេរ្តិ៍ឈ្មោះនៅលើឆាកអន្តរជាតិ។ រីឯតំបន់ជនបទនៅទូទាំងប្រទេស ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ គឺមានហេដ្ឋារចនាសម្ព័ន្ធស្ពាន ផ្លូវថ្នល់ខ្វាត់ខ្វែង មានប្រព័ន្ធធារាសាស្ត្រ ការតភ្ជាប់អគ្គិសនី សេវាព្យាបាល និងថែទាំសុខភាពនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក និងការទទួលបានសេវាទឹកស្អាត និងអនាម័យ ដែលទាំងអស់នេះគឺជាការអន្តរាគមន៍ពហុវិស័យ សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន សុខភាពប្រជាជន និងអាហារូបត្ថម្ភ ដើម្បីគាំទ្រការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម ប្រកបដោយចីរភាព។ ក្នុងផ្នែកគាំពារសង្គម រាជរដ្ឋាភិបាលបានដាក់ចេញ និងអនុវត្ត **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥** មានភាពគ្រប់ជ្រុងជ្រោយ ដែលក្របខណ្ឌគោលនយោបាយនេះមានសង្គតិភាពទៅនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងឯកសារគោលនយោ-បាយសំខាន់ៗ ជាពិសេសយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ។

៦.	ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំមានមោទនភាពពីសមិទ្ធផលដ៏ធំធេងរបស់កម្ពុជាដែលសម្រេចបានកន្លងមក ពិសេសក្នុងការឆ្លើយតបទៅនឹងគ្រោះអត់ឃ្លាន និងបញ្ហាអាហារូបត្ថម្ភ ដូចបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍សន្ទស្សន៍ឆ្នាំ២០១៧ ស្តីពីគ្រោះអត់ឃ្លានសកល។ ទោះបីកម្ពុជានៅមានបញ្ហាខ្លះៗដែលជួបប្រទះគ្រោះអត់ឃ្លាន ក៏ប៉ុន្តែកម្ពុជាសម្រេចបាននូវការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយបច្ចុប្បន្ននេះ កម្ពុជាកំពុងឈានទៅសម្រេចបាននូវស្ថានភាពជាប្រទេសមួយ ដែលមានបញ្ហាគ្រោះអត់ឃ្លានតិចតួច ហើយកម្ពុជាក៏សម្រេចបាននូវពិន្ទុមួយខ្ពស់បំផុតក្នុងការកាត់បន្ថយភាពអត់ឃ្លាន ដែលត្រូវបានវាស់វែងតាមរយៈសន្ទស្សន៍ពិន្ទុនៃគ្រោះអត់ឃ្លានសកលពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៧ ។

៧.	ការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងសង្គម បានធ្វើឲ្យប្រជាជនផ្លាស់ប្តូររបៀបរស់នៅ និងការហូបចុក។ ការផ្លាស់ប្តូរទម្លាប់ក្នុងសង្គមនេះ មានឥទ្ធិពលលើស្ថានភាពអាហារូបត្ថម្ភ ហើយបញ្ហាប្រឈមថ្មីៗ ក៏កំពុងលេចចេញជារូបរាងឡើងដែរ ខណៈពេលដែលកម្ពុជាជួបការលំបាកមួយចំនួន ដូចជាការដោះស្រាយជាអន្តរវិស័យបញ្ហាក្មេងក្រិសក្រិន ក្មេងស្គមស្គាំង បញ្ហាអត្រាការបំបៅកូនដោយទឹកដោះម្តាយមួយមុខគត់បាន

ថយចុះ បញ្ហាលើសទំងន់ និងបញ្ហាធាត់ជ្រុលមាននិន្នាការកើនឡើង ជាពិសេសក្នុងចំណោមស្ត្រីវ័យបន្តពូជ។ បញ្ហានេះបង្កផលប៉ះពាល់ដល់ស្ត្រីក្នុងវ័យបន្តពូជកាន់តែច្រើនឡើងៗ ខណៈពេលដែលការផ្លាស់ប្តូរទម្លាប់ហូបចុក និងករណីជំងឺមិនឆ្លង បាននិងកំពុងដាក់សម្ពាធមកលើប្រព័ន្ធសុខភាពសាធារណៈ ហេតុផលទាំងអស់នេះយើងចាំបាច់ត្រូវរៀបចំច្បាប់ ស្តីពីសុវត្ថិភាពអាហារ លិខិតបទដ្ឋានគតិយុត្តិគ្រប់គ្រងទីផ្សារ និងស្លាកសញ្ញាសម្គាល់ផលិតផល។

៨. ការបន្តយកចិត្តដាក់លើការវិនិយោគ និងការអន្តរាគមន៍ពហុវិស័យ ដើម្បីកាត់បន្ថយបញ្ហាអាហារូបត្ថម្ភ គឺនៅតែជារបៀបវារៈដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ដោយក្នុងនោះយើងទាំងអស់គ្នាត្រូវធ្វើការរួមគ្នា ដើម្បីឱ្យប្រជាជនគ្រប់រូបទទួលបាន **អាហារូបត្ថម្ភល្អ មានសុខភាពល្អ** ។ ការទទួលបានអាហារូបត្ថម្ភល្អ គឺធ្វើឱ្យមនុស្សជំនាន់ក្រោយ ជាពិសេសកុមារដែលជាមូលធនមនុស្សសម្រាប់បន្តវេនក្នុងការអភិវឌ្ឍប្រទេសជាតិ និងមាតុភូមិយើងមានអនាគតល្អ។ រាជរដ្ឋាភិបាលកម្ពុជាសូមប្តេជ្ញានៅតែបន្តពន្លឿនវឌ្ឍនភាព ដើម្បីឆ្លើយតបចំពោះបញ្ហាអាហារូបត្ថម្ភ និងខិតខំធ្វើឱ្យសម្រេចបាននូវគោលដៅរួម គឺការកាត់បន្ថយគ្រោះអត់ឃ្លាន និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដើម្បីកម្ពុជាបោះជំហានឱ្យកាន់តែកៀកនឹងគោលដៅ "**ដោយមិនទុកឱ្យនរណាម្នាក់មានបញ្ហាកង្វះស្បៀង និងរងគ្រោះពីបញ្ហាអាហារូបត្ថម្ភ**"។

៩. ជាទីបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តកិច្ចសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីរួមគ្នា**បញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង និងលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជា។** ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ តំណាងអង្គការជាតិ អន្តរជាតិ អស់លោក លោកស្រី អ្នកនាង កញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំង៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរឱ្យដំណើរកំសាន្តក្នុងពិធីបុណ្យឯករាជជាតិ ៩ វិច្ឆិកា ខាងមុខនេះ ទទួលបានភាពសប្បាយរីករាយ និងមានសុវត្ថិភាព។

**សូមអរគុណ** !